ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

10-06-2013
16:00

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ២០១៣

នៅក្នុងខែឧសភានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មពាក់ព័ន្ធនឹងដំណើរការរៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់នានា ការធ្វើរបាយការណ៍ និងការងារពាក់ព័ន្ធផ្សេងទៀតជាច្រើន ។ ជាពិសេសការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កសាងគោលនយោបាយសង្គមកិច្ច និងបានពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិយ៉ាងទូលំទូលាយ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

-ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ប្រជុំវិសាមញ្ញ និងពេញអង្គព្រឹទ្ធសភា នីតិកាលទី៣ ចំនួន០៤លើក ។ បានជួបប្រជុំពិភាក្សាជាមួយ ឯកឧត្តម លោកជំទាវ ជាប្រធានគណៈកម្មការ អញ្ជើញជាកិត្តិយសក្នុងពិធីចុះហត្ថលេខាប្រគល់-ទទួលហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ដែលជាអំណោយរបស់ Rimbunan Hijau Group នៃប្រទេសម៉ាឡេស៊ី ជូនដល់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជួបពិភាក្សាការងារជាមួយសាស្ត្រាចារ្យ Surya Prasad Subedi អ្នកធ្វើរបាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធមនុស្សក្នុងព្រះរាជាណាចក្រកម្ពុជា និងលោក Denis Schrey តំណាងប្រចាំព្រះរាជាណាចក្រកម្ពុជារបស់មូលនិធិខុនរ៉ាដអាឌិនណៅអ៊ែរ (KAS) និងបន្តជម្រុញការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ប្រជុំពិភាក្សាការងារ និងបានពិនិត្យសម្រេចលើឯកសារផ្សេងៗចំនួន៣៤៨ច្បាប់ ។

**១.សេវាទទួលបន្ទុកខាងនីតិកម្ម**

-បានរៀបចំដំណើរការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ កិច្ចប្រជុំវិសាមញ្ញ និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០៤លើក និងបានសិក្សាវិភាគ និងធ្វើរបាយការណ៍លើសេចក្តីព្រាងច្បាប់ចំនួន០៧ ។

**២.សេវាទទួលបន្ទុកខាងត្រួតពិនិត្យ**

-បានចុះបំពេញការងារជាមួយគណៈកម្មការទី៤ និងគណៈកម្មការទី៧ ក្នុងជំនួបសវនាការជា

មួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីស្វែងយល់អំពីលទ្ធផលការងារ និងការរីកចម្រើនវិស័យវប្បធម៌ និងវិចិត្រសិល្បៈ ជាពិសេសដើម្បីបង្កើននូវកិច្ចទំនាក់ទំនងឲ្យកាន់តែជិតស្និទ្ធរវាងក្រសួង និងគណៈកម្មការ និងជាមួយក្រសួងព័ត៌មាន ដើម្បីស្វែងយល់អំពីសកម្មភាពការងារដែលក្រសួងសម្រេចបាន និងទិសដៅសម្រាប់អនុវត្តការងារគ្រប់គ្រងកាសែត ទស្សនាវដ្ដី វិទ្យុ ទូរទស្សន៍ ពេងពុម្ពព្រឹត្តិប័ត្រ សារព័ត៌មានផ្សេងៗ និងបញ្ហាផ្សព្វផ្សាយពាណិជ្ជកម្ម ដំណើរការនៃការកសាងសេចក្ដីព្រាងច្បាប់ស្ដីពី សិទ្ធិទទួលព័ត៌មាន ការត្រៀមផែនការយុទ្ធសាស្ត្ររបស់ក្រសួងក្នុងការធ្វើសមាហរណកម្មវិស័យព័ត៌មានរបស់កម្ពុជាក្នុងសហគមន៍អាស៊ាននៅឆ្នាំ២០១៥ ខាងមុខ។

-តាមដានការអនុវត្តបទបញ្ជាផ្ទៃក្នុង ត្រួតពិនិត្យការអនុវត្តផែនការការងារប្រចាំខែនីមួយៗនៅគ្រប់អង្គភាព និងបានត្រួតពិនិត្យប័ណ្ណចំណូល-ចំណាយទូទៅរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

**៣.សេវាទំនាក់ទំនងមុខងារតំណាងៈ**

-រៀបចំ និងអមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះទៅតាមបណ្ដាខេត្ត-រាជធានីទូទាំងប្រទេសចំនួន១៣៧លើក ដើម្បីសំណេះសំណាល សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ចែកប័ណ្ណកម្មសិទ្ធិដីធ្លី ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៨២លើក ។

-ទទួលពាក្យបណ្ដឹងចំនួន០៣ករណី និងបានធ្វើលិខិតអន្តរាគមន៍ជូនទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយបានចំនួន០៨ករណី ។

**៤.សេវាទំនាក់ទំនងមុខងារព័ត៌មានៈ**

-រៀបចំបែបបទ និងអមដំណើរសមាជិក-សមាជិកាព្រឹទ្ធសភា ចុះបំពេញបេសកកម្មទៅខេត្តកំពតដើម្បីសិក្សាស្វែងយល់អំពីការអនុវត្តន៍ច្បាប់របស់តុលាការ អយ្យការ ខេត្ត និងមន្ត្រីភ្នាក់ងារនគរបាលយុត្តិធម៌ និងរបៀបដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ឃុំ នៅខេត្តកំពត ។

**៥.ការងារអន្តរជាតិៈ**

-រៀបចំជំនួបសម្ដែងការគួរសមរវាង ឯកឧត្តម សាយ ឈុំ អនុប្រធានទី១ព្រឹទ្ធសភា នៃ

ព្រះរាជាណាចក្រកម្ពុជា ជាមួយប្រធានព្រឹទ្ធសភានៃសហព័ន្ធស្វីស និងឯកឧត្តម Yuji KUMAMARU ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ។

-រៀបចំបែបបទ អមដំណើរ ឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា អញ្ជើញចូលរួមកិច្ចប្រជុំ AIPA-Caucus លើកទី៥ នៅទីក្រុងដាឡាត នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

-បានទំនាក់ទំនងនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអន្តរជាតិ ស្ថានកុងស៊ុលបែលហ្ស៊ិក ស្ថានកុងស៊ុលន័រវែស ស្ថានទូតPhilippine ឥណ្ឌា ម៉ាឡេស៊ី រុស្ស៊ី មីយ៉ាន់ម៉ា ប្រុយណេ ថៃ ឡាវ ដាណឺម៉ាក Singarpore ឥណ្ឌូនេស៊ី អូស្ត្រាលី ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

**៦.ទំនាក់ទំនងសាធារណៈ៖**

-បានទំនាក់ទំនងជាមួយក្រសួងមហាផ្ទៃ ក្រសួងការបរទេស ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាជ្ញាធរអប្សរា និងអភិបាលខេត្តក្រុង ដើម្បីសម្រួលបែបបទជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ទៅបំពេញបេសកកម្មក្នុង និងក្រៅប្រទេស និងទំនាក់ទំនងជាមួយសាកលវិទ្យាល័យ CUS, CMTC, CDC, AEU, ECCC, CWF, NiDA, Honh kong Center ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា។

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត សាធារណៈជន ចូលអានសៀវភៅ ចំនួន៣៣៨នាក់ ។

**៧.ការអភិវឌ្ឍធនធានមនុស្ស៖**

-បានបើកវគ្គបណ្តុះបណ្តាល ស្តីពីវគ្គភាសាអង់គ្លេសសម្រាប់មន្ត្រីសភាកម្ពុជា វគ្គការប្រើប្រាស់ភាសាខ្មែរក្នុងការសរសេរឲ្យបានត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ វគ្គភាសាចិនបន្ត(ជំហានទី៣ និងជំហានទី២) វគ្គវិភាគច្បាប់ និងភាសាអង់គ្លេស ។

-អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ចំនួន២២នាក់ ។

+ ការបណ្តុះបណ្តាលធនធានមនុស្សក្រៅប្រទេស

-មន្ត្រីចំនួន០៩រូប ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីទិដ្ឋភាពយេនឌ័រ ក្រោយពីប្តូរពីរបបយោធាទៅរបបសង្គមស៊ីវិល វគ្គស្តីពីវិធីសាស្ត្របង្រៀន និងភាពជាអ្នកគ្រប់គ្រងថ្នាក់រៀន និងវគ្គភាសាចិន នៅប្រទេសចិន

- មន្ត្រី១២នាក់ ចូលរួមវគ្គបណ្តុះបណ្តាលផ្នែក ICT នៅវៀតណាម ។

**៨.ការអភិវឌ្ឍស្ថាប័ន៖**

-បន្តការសាងសង់អគារ ០៣ខ្នង ០៣ជាន់ ការបំពាក់ជណ្តើរយន្ត ការជម្រុញគម្រោងជំនួយសុំបន្ថែម និងអនុវត្តបញ្ចប់គម្រោងបច្ចេកវិទ្យាក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន Camserv

Cambodia (ម៉ាឡេស៊ី)។ ការលាបថ្នាំនាយកដ្ឋានរដ្ឋបាល សាលពិសេស សាលសិក្ខាសាលាខាងជើង ដំណើរការកំចាត់សត្វល្អិតនៅអាគារក្រហម ។

**៩.សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែងៈ**

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន១៥លើក ។

-ថតចម្លងឯកសារ ចំនួន៩៥សំណើ និងចងក្រងឯកសារជាសៀវភៅ ចំនួន០៣ក្បាល ដោះស្រាយសម្ភារ ចំនួន៥១សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូន ចំនួន៨៧លើក ។

-តម្លើង បញ្ចូលហ្គាស ជួសជុល ទូរទស្សន៍ ព្រីនធ័រ ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនថតចម្លង ទូទឹកកក ទូរស័ព្ទ កៅអីវិលធំ សោគុ ឌីសង់ទ័រ បន្ទប់ទឹក បណ្តាញអគ្គិសនី ប្តូរអំពូល ព្រី កុងតាក់ ចំនួន១០១គ្រឿង បិទលេខកូដកុំព្យូទ័រយួរដៃ ចំនួន៨០គ្រឿង និងប្រគល់កុំព្យូទ័រយួរដៃ ទៅគ្រប់អង្គភាព ចំនួន ១០០គ្រឿង និងបានជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode,Office ចុះតាមដាន Internet និង Network សរុបចំនួន១០៣គ្រឿង និងបានUpload ព័ត៌មាន និងឯកសារផ្សេងៗចំនួន៥០ប្រធានបទ ។

**II.ទិសដៅការងារខែឧសភា ឆ្នាំ២០១៣**

១-ត្រៀមរៀបចំសម័យប្រជុំពេញអង្គ ។

២-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយ គណៈប្រតិភូជាតិអន្តរជាតិ និងអង្គទូតនានា ។

៣-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត។

៤-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស។

៥-ត្រៀមរៀបចំសម្រាប់ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ និងទិវាកុមារអន្តរជាតិ ។

៦-តាមដានកម្មវិធីសច្ចាប្រណិធានរបស់សមាជិកព្រឹទ្ធសភាថ្មី ចំនួន០៧រូប។

៧-ដាក់ដេញថ្លៃលើកទី២ លើគម្រោងដណ្តើរយន្ត កាប៊ីនភ្លើង អាងស្តុកទឹក លូទឹក ផ្លូវថ្នល់ សួនច្បារ និងជួសជុលអគារ ។

៨-ដាក់ទុងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាឆ្នាំ២០១៤របស់ព្រឹទ្ធសភាជូនគណៈកម្មការទី២ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៩-ពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ គ្រប់អង្គភាពអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆមាសទី១ ឆ្នាំ២០១៣ ។

១០-បន្តការបណ្តុះបណ្តាល និងការរកអាហារូបករណ៍ក្នុង និងក្រៅប្រទេសដល់មន្ត្រី ។

១១-បន្តជម្រុញការដ្ឋានសាងសង់អគារ០៣ខ្នង និងបន្តស្វះស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការ ។

III.**សេចក្តីសន្និដ្ឋាន**

ក្នុងខែឧសភានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងមមាញឹកក្នុងការធ្វើរបាយការណ៍ចន្លោះសម័យប្រជុំ របាយការណ៍តាមវិស័យ រៀបចំប្រជុំគណៈកម្មការជំនាញ គណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំវិសាមញ្ញ ប្រជុំពេញអង្គលើកទី៣ ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៧ និងការទទួលគណៈប្រតិភូព្រឹទ្ធសភាស៊ីស ។

ភ្នំពេញ,ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣

**អគ្គលេខាធិការ**

**អ៊ុំ សារិទ្ធ**